**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**លេខ**......................

# សេចក្ដីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ **ឯកឧត្តម អគ្គលេខធិការនៃអង្គការសហប្រជាជាតិ** (អ.ស.ប) **អង់តូនីញ៉ូ ហ្គូតេរេ** (Antonio Guterres) **សម្ដេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារ**ជាតិ**នឹងដឹកនាំគណៈប្រតិភូយោធាជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ(ខ.ភ.ម) ចាកចេញពីព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ ដើម្បីចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិស្ដីពីកិច្ចការរក្សាសន្តិភាពអង្គការសហប្រជាជាតិ (អ.ស.ប) ក្នុងទីក្រុង ញូវយ៉ក សហរដ្ឋអាមេរិក។

ក្នុងអំឡុងពេលបំពេញការងារ ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩ **សម្ដេចពិជ័យសេនា ទៀ បាញ់** ព្រមទាំងប្រតិភូយោធាជាន់ខ្ពស់ ខ.ភ.ម នឹងអញ្ជើញចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិស្ដីពី **កិច្ចការរក្សាសន្តិភាព អ.ស.ប ឆ្នាំ២០១៩** (2019 United Nations Peacekeeping Ministerial on Uniformed Capabilities , Performance and Protection) ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៩ ខែមីនា នៅទីស្នាក់ការ អ.ស.ប ក្នុងទីក្រុងញូវយ៉ក ក្រោមអធិបតីភាព **ឯកឧត្តម អគ្គលេខធិការ អ.ស.ប អង់តូនីញ៉ូ ហ្គូតេរេ** (Antonio Guterres )។

កិច្ចប្រជុំនឹងផ្ដល់វេទិកា និងបង្កើតសមត្ថភាពជំនាញចាំបាច់សម្រាប់ប្រតិបត្តិការរក្សាសន្តិភាពនាពេលបច្ចុប្បន្ន ក៏ដូចជាឆ្លុះបញ្ចាំងពីកិច្ចប្រឹងប្រែងពង្រឹងការងារនេះតាមរយៈគំនិតផ្ដួចផ្ដើម សកម្មភាពសម្រាប់ការរក្សាសន្តិភាព (Action for Peacekeeping "A4P") របស់ ឯកឧត្តម អគ្គលេខាធិការ ដោយផ្ដោតលើសមត្ថភាពជំនាញ ការអនុវត្តន៍ និងការការពារជនស៊ីវិល។ កិច្ចប្រជុំនឹងផ្ដោតលើលទ្ធផលនៃការពិភាក្សាក្នុងកិច្ចប្រជុំត្រៀមទាំង៣កន្លងមកក្នុងទីក្រុង ម៉ុងតេវីដេអូ (Montevideo) ទីក្រុង ឡាអេ (The Hague) និង ទីក្រុង អាឌីស អាបាបា (Addis Ababa) ៕

*ថ្ងៃច័ន្ទ ៥រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២*

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៨ អ៊ីម៉ែល៖ generalsec@mod.gov.kh